# របៀបនៃការបង្កើតមតិរួម

## តើមតិរួមមានអត្ថន័យយ៉ាងដូចម្ដេច?

យើងបានសាកសួរមនុស្សមួយចំនួនពីអ្វីដែលពួកគេបានយល់ពីអត្ថន័យនៃ **មតិរួម** ។ ទាំងនេះគឺជាចម្លើយមួយចំនួនដែលពួកគាត់បានឆ្លើយ ៖



"មតិដែលបានឯកភាពគ្នាលើទស្សនៈជាច្រើនគឺចេញពីលទ្ធផលនៃការពិភាក្សារបស់ក្រុមសហគមន៍មួយ ឬច្រើន ដើម្បីធ្វើយ៉ាងណាឱ្យស្ថានភាព និងលក្ខខណ្ឌរបស់សហគមន៍ បានកាន់តែល្អប្រសើរឡើង ។ "

"ការព្រមព្រៀង ឬយល់ស្របគ្នានូវវិធីសម្រាប់ដំណើរការទៅថ្ងៃមុខ ។"

"ការសម្រេចចិត្តជារួមរបស់ក្រុមពោរពេញទៅដោយទស្សនៈ និងមតិទូលំទូលាយ លើបញ្ហាដ៏ច្បាស់លាស់ ។"

មតិរួមមានន័យថាជាការព្រមព្រៀងយោគយល់គ្នាលើគំនិត ទស្សនៈ និងមតិ ។

**ដូចនេះ**

**ការកសាងមតិរួមគឺ**

វិធីដែលឈានដល់ការសម្រេចចិត្តរួមដែលអាចទទួលយកបានស្ទើរតែគ្រប់អ្នកពាក់ព័ន្ធទាំងអស់ដែលមានមតិ និងទស្សនៈទូលំទូលាយលើប្រធានបទ ឬបញ្ហាជាក់លាក់ណាមួយ ។

## ស្ដីពីរបៀបនៃការបង្កើតមតិរួម

មនុស្សមួយចំនួនធំធ្វើការយ៉ាងសកម្មដើម្បីធ្វើយ៉ាងណាជួយស្ដារស្ថានភាពរបស់សហគមន៍ណាដែលពុំទទួលបាននូវផលប្រយោជន៍ ។ អ្នកទាំងនោះគឺជាអ្នកបម្រើការងារនៅក្នុងស្ថាប័នរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងគម្រោងអភិវឌ្ឍន៍នានាដែលសុទ្ធតែជាអ្នកមានសមត្ថភាពជំនាញច្រើនមុខ ។

ខ្ញុំពេញចិត្តឱ្យអ្នករាល់គ្នាបានដឹងពីការពុះពារដែលខ្ញុំជួបប្រទះ ។

អ្នកនេសាទ និងកសិករក៏មានជំនាញរបស់គាត់ផងដែរ តាមរយៈបទពិសោធន៍ប្រចាំជីវិតផ្ទាល់ខ្លួនគាត់នៅក្នុងស្ថានភាពទូទៅ និងអ្វីខ្លះដែលពួកគាត់គួរធ្វើការកែប្រែវា ។

ប្រសិនបើយើងដឹងពីនរណាម្នាក់ យើងអាចចាប់ផ្ដើមរក ដំណោះស្រាយដែលល្អៗសម្រាប់យើងទាំងអស់គ្នា ។



ឥឡូវនេះ ខ្ញុំមានសង្ឃឹមកាន់តែច្រើនឡើង ។



ព័ត៌មានដែលអ្នកនេសាទ និងកសិកររៀបរាប់អំពីជីវិតរបស់ពួកគាត់អាចផ្ដល់ឱ្យយើងយល់បានគ្រប់គ្រាន់ពីការពិតនៃបទពិសោធន៍របស់ពួកគាត់ ។ ពួកគាត់អាចជួយដល់អ្នកនយោបាយឱ្យបានយល់កាន់តែច្បាស់ពីរបៀបរស់នៅដ៏លំបាកស្មុកស្មាញ និងបំណងប្រាថ្នា "**អ្នកទទួល**" ៖ ស្ត្រីក្រីក្រ បុរស និងយុវជន រួមមានក្រុមជនជាតិភាគតិច និងក្រុមមនុស្សផ្សេងៗទៀត ។ ពួកគាត់អាចផ្ដល់ឱ្យនូវប្រភពព័ត៌មានគ្រប់យ៉ាងសម្រាប់ជាជំនួយក្នុងការពិភាក្សានយោបាយ និងឈានដល់ការសម្រេចចិត្តក្នុងការកែប្រែនយោបាយនោះ ។

របៀបនៃការកសាងមតិរួមគឺជាវិធីមួយផ្ដល់នូវទីកន្លែងដែលអាចប្រាប់នូវរឿងរ៉ាវទាំងអស់ដល់យើង ដូចនេះ គ្រប់នយោបាយទាំងអស់អាចជួយធ្វើឱ្យប្រសើរឡើងដល់សេចក្ដីត្រូវការរបស់អ្នកក្រីក្រ ។

## តើរបៀបកសាងមតិរួមត្រូវបំពេញការងារយ៉ាងដូចម្ដេចខ្លះ?

ក្នុងគម្រោង STREAM ហៅថា *នយោបាយតាមដានធ្វើឱ្យប្រសើរឡើងនូវបទដ្ឋានវារីវប្បកម្មសម្រាប់អ្នកក្រីក្រ* អ្នកពាក់ព័ន្ធជាច្រើន បានចូលរួមជាមួយគម្រោងការអភិវឌ្ឍន៍ ដើម្បីជួយដល់សហគមន៍ជនជាតិភាគតិចឱ្យចេះចិញ្ចឹមត្រី ៖ សហគមន៍ជនជាតិភាគតិច អ្នកស្រាវជ្រាវ អ្នកនយោបាយ និងអ្នកពាក់ព័ន្ធផ្សេងៗទៀត ។

មនុស្សផ្សេងៗគ្នាតែងមានទស្សនៈផ្ទុយគ្នា ។ ភាពផ្ទុយគ្នាទាំងអស់នេះអាចជាទស្សនៈស្ដីពីគោលដៅ លទ្ធផលសម្រេចបាន និងសកម្មភាពនៃគម្រោងដែលនឹងត្រូវធ្វើ និងវិធី ហើយនឹងថាតើនរណាជាអ្នកអនុវត្ត ។ STREAM បានប្រើ a Consensus-Building Process ដើម្បីឱ្យប្រាកដថា ទស្សនៈរបស់មនុស្សម្នាក់ៗត្រូវបានគេដឹងឮ ។

ក្នុងដំណើរការនេះ សមាជិកម្នាក់ៗរបស់ "ក្រុម" បានស្គាល់នូវសមាជិកក្រុមដ៏ទៃទៀត ប៉ុន្តែអ្នកទាំងអស់នោះបំពេញការងាររៀងៗខ្លួន ។ នៅដំណាក់កាលទី ១ អ្នកបង្កើតនយោបាយរបស់រដ្ឋ និងរបស់រដ្ឋាភិបាលថ្នាក់ជាតិត្រូវតែផ្ដល់នូវទស្សនៈ ឬមតិរបស់ខ្លួនលើការផ្លាស់ប្ដូរនយោបាយ ។ ទាំងនេះ នឹងបង្កើតឡើងនូវទស្សនៈ និងការជំទាស់របស់ក្រុមខ្លះៗ ។

មជ្ឈន្តិកផ្ដល់នូវការឆ្លើយតបរបស់ពួកគេ និងផ្ដល់ដល់អ្នកចូលរួមផងដែរ ។ បន្ទាប់មក ពួកគេនឹងទទួលបាននូវការពន្យល់ពីអ្នកចូលរួមពីដំណើរការដែលពាក់ព័ន្ធ ប៉ុន្តែគេមិនបញ្ចេញឱ្យដឹងពីការពន្យល់ណាមួយជាមតិរបស់អ្នកចូលរួមណាម្នាក់ឡើយ ។ ក្រោយមក ពួកគេអាចឈានដល់ការព្រមព្រៀង ឬមិនព្រម និងត្រូវធ្វើការផ្លាស់ប្ដូរទស្សនៈគ្នាយ៉ាងដូចម្ដេចបន្តទៀត ដោយពុំមានបញ្ចេញឈ្មោះនរណាម្នាក់ឡើយ ។

បន្ទាប់មក អ្នកចូលរួមក្នុងដំណើរការទាំងអស់ត្រូវបានគេស្នើសុំឱ្យទទួលយកនូវការឆ្លើយតបពីមជ្ឈន្តិកី និងធ្វើការគាំទ្រដល់ការងារនោះ ។ ពួកគេក៏ត្រូវតែផ្លាស់ប្ដូរនូវទស្សនៈរបស់ពួកគេឱ្យស្របគ្នាទៅនឹងមតិរួមថ្មីដែលបានសម្រេចចេញនោះ ឬក៏គេអាចបដិសេធវា ហើយផ្ដល់នូវការរីកញែកបន្ថែមទៀត ថាតើហេតុអ្វីដែលត្រូវផ្លាស់ប្ដូរគំនិតរបស់គេនោះ ។

ក្នុងករណីនេះ អ្នកបង្កើតនយោបាយត្រូវបានគេលើកសួរដើម្បីជ្រើសរើសយកចេញពីជម្រើសអត្ថិភាពផ្លាស់ប្ដូរចំនួន ៤២ ដែលបានស្នើឡើងដោយអ្នកចូលរួមរបស់គម្រោង ។ លទ្ធផលនេះបានមកពីអនុសាសន៍ជាអត្ថិភាពចំនួន ១៣ សម្រាប់ធ្វើការផ្លាស់ប្ដូរគោលនយោបាយ ។

## ការពាក់ព័ន្ធនឹងរបៀបនៃការបង្កើតមតិរួម...

...មានពេលវេលាដើម្បីកសាងទំនុកចិត្ត បន្តទំនាក់ទំនងក្នុងចំណោមអ្នកពាក់ព័ន្ធទាំងអស់ ធ្វើការដូចមនុស្សតែមួយ ភូមិតែមួយ និងស្ថាប័នតែមួយ ។

...ជួយឱ្យអ្នកទាំងអស់បញ្ចេញទស្សនៈក្នុងទិដ្ឋភាពស្ថាបនា និងជួយគ្នាទៅវិញទៅមក ។



...មនុស្សមួយចំនួនណាមិនសូវមានការយល់ដឹងលើការសម្រេចចិត្តផ្នែកនយោបាយ និងដំណើរការនៃការងារខាងក្រៅ ដើម្បីនឹងធ្វើឱ្យនយោបាយលុបបំបាត់ភាពក្រីក្រអាចត្រូវបានធ្វើឱ្យកាន់តែប្រសើរឡើង ។

...ផ្ដល់នូវទីកន្លែង និងពេលវេលាសម្រាប់រួមគំនិតគ្នា ៖ ធ្វើសេចក្ដីថ្លែងការណ៍ ល្ខោនកុន និងវីដេអូល្អៗ ។

...ប្រើប្រាស់គ្រប់សកម្មភាពដែលអាចជួយសម្រួលដល់ការចូលរួមឱ្យបានស្មើភាពគ្នា ។

...ស្ដាប់នូវមតិរបស់ប្រជាជន ជាពិសេសអ្នកក្រីក្រ ។

...ផ្ដល់ជាអនាមិកភាព និងឱកាសដល់អ្នកខាងក្រៅគ្រប់ថ្នាក់ ដូចជា នាំអ្នកទាំងនោះឱ្យបានស្វែងយល់ពីអ្វីដែលកើតមាននៅខាងក្រៅ ដូចនេះគេអាចធ្វើការរួមគ្នា "**ជាអព្យាក្រិត្យ**" ដើម្បីរួមទស្សនវិស័យទាំងអស់គ្នា ។

# ក ៧ - ជំហាននៃដំណើរការកសាងមតិរួម : ទស្សនៈ

បាទ យើងដឹង ថាខ្ញុំនេះជាស្ត្រីចំណាស់ និងមានបទពិសោធន៍ជាច្រើននៅក្នុងជីវិត ។ ប៉ុន្តែ ខ្ញុំមិនដែលឃើញអ្នកក្រីក្រណាម្នាក់ក្លាយជាអ្នកធ្វើការផ្លាស់ប្តូរនយោបាយឡើយ ។

**១- ការពិភាក្សាថ្នាក់មូលដ្ឋាន**

ការពិភាក្សាជាមួយអ្នកនេសាទ និងកសិករ

- ក្រុមកសិករ ការប្រជុំរបស់សហករណ៍ភូមិ
- ភូមិ គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ  សិក្ខាសាលាថ្នាក់ក្រុង
- ស្រុក រដ្ឋ សិក្ខាសាលាថ្នាក់ខេត្ត

**២- ប្រមូលផ្តុំរាល់បញ្ហា**

ធ្វើពង្រាងនូវរាល់បញ្ហា និងអត្ថិភាពដែលបានលើកឡើងដោយសហគមន៍

**៣- លំដាប់ថ្នាក់អត្ថិភាព**

លើកឡើងនូវរាល់បញ្ហាជូនទៅអ្នកនយោបាយគ្រប់ជាន់ថ្នាក់ដើម្បីធ្វើលំដាប់ថ្នាក់អត្ថិភាពទៅតាមមតិរបស់ពួកគេ

**៤- ធ្វើសេចក្តីសង្ខេប**

ធ្វើសេចក្តីសង្ខេបលំដាប់អត្ថិភាពរបស់អ្នកបង្កើតនយោបាយ

**៥- ធ្វើបទបង្ហាញចុងក្រោយ**

លើកឡើងពីលំដាប់ថ្នាក់អត្ថិភាពយ៉ាងសង្ខេបសម្រាប់ដាក់ឱ្យធ្វើការពិភាក្សាជាចុងក្រោយរវាងអ្នកធ្វើនយោបាយ និងកសិករ

លោកយាយ សូមអានរឿងស្តីអំពី *Mahajal* យាយ នឹងបានដឹងពីរបៀបដែលយើងអាចផ្លាស់ប្តូរនយោបាយ ។

**៦- ឈានដល់ការបង្កើតនយោបាយ**

ប្រែក្លាយអនុសាសន៍ដែលបានលើកឡើងឱ្យក្លាយទៅជានយោបាយ

**៥- ផ្លាស់ប្តូរនយោបាយ**









## *Mahajal* – **បណ្តាញនេសាទដ៏ធំមួយ**

មានឆាកសម្តែង *Mahajal* - **បណ្តាញនេសាទដ៏ធំមួយ** ដែលបានសម្តែងជូនអ្នកនយោបាយនៅមុខស្ថានប័នកណ្តាលរបស់រាជរដ្ឋាភិបាលទស្សនា ។ ការសម្តែងបានបង្ហាញពីជីវិតពិត១របស់ប្រជាជន និងការលំបាកដែលគេជួបប្រទះក្នុងជីវភាពរស់នៅរបស់ពួកគាត់ ។ រឿងរ៉ាវទាំងអស់នេះ ត្រូវបានគេរៀបរាប់ជាលើកដំបូងក្នុងអំឡុងពេលកំពុងដំណើរការកសាងមតិរួម ។

ការសម្តែងនេះបានបង្ហាញប្រាប់ដល់អ្នកនយោបាយឱ្យបានដឹងពីការព្រួយបារម្ភរបស់អ្នកក្រីក្រ ។ ក្នុងពេលនោះ អ្នកនយោបាយបានទទួលយកអនុសាសន៍ចំនួន ១៣ សម្រាប់ធ្វើការពិចារណា ។



# សារៈសំខាន់មួយចំនួនពីរបៀបនៃការបង្កើតមតិរួម




ពេលខ្លះ ការសម្រេចចិត្តរបស់ក្រុមអាចមានការពិបាក ពីព្រោះនៅក្នុងក្រុម មានមនុស្សគ្រប់ប្រភេទដែលមានបុគ្គលិកលក្ខណៈ និងស្ថានភាពខុសៗគ្នា ។ ជាឧទាហរណ៍ សមាជិកខ្លះនិយាយច្រើនលើសគេឯង ផ្ទុយទៅវិញ សមាជិកខ្លះទៀតពុំមានមតិអ្វីសោះ ។ សមាជិកខ្លះមានការខ្មាសអៀនពុំហ៊ានបញ្ចេញមតិនៅចំពោះអ្នកដែលជាចៅហ្វាយនាយរបស់ខ្លួនឡើយ ។ បច្ចេកទេសនៃដំណើរការបង្កើតមតិរួមនាំមកនូវផលប្រយោជន៍ដល់ការសម្រេចចិត្តរបស់ក្រុម ដែលអាចជៀសវាងនូវដែនកំណត់របស់បញ្ហាមួយចំនួន ឧទាហរណ៍ ការលុបលើរបស់សមាជិកក្រុមមួយចំនួន ការបញ្ចុះបញ្ចូលផ្នែកនយោបាយ **“គឺពុំមែនជាការចង់រឹះគន់ចៅហ្វាយនាយឡើយ ។ ”**

## អាសយដ្ឋានទំនាក់ទំនងសំខាន់ៗ

## គោលការណ៍ណែនាំអនុវត្តឱ្យកាន់តែល្អប្រសើរផ្សេងៗទៀត

មានគោលការណ៍ណែនាំអនុវត្តឱ្យកាន់តែល្អប្រសើរផ្សេងៗទៀត រួមមាន :

- ការកសាងមតិឯកភាពគ្នាជារួម
- ក្រុមជួយដោយខ្លួនឯង

លោកអ្នកអាចទទួលបានឯកសារទាំងអស់នេះ និងឯកសារគោលការណ៍ណែនាំអនុវត្តឱ្យកាន់តែប្រសើរផ្សេងទៀតពីការិយាល័យ STREAM នៅតាមប្រទេសរបស់អស់លោកអ្នក ពីការិយាល័យ STREAM ប្រចាំតំបន់ ឬពីគេហទំព័ររបស់ STREAM ។

យើងខ្ញុំសូមទទួលយកនូវរាល់ការរិះគន់ស្ថាបនាពីអស់លោកអ្នក នូវរាល់គោលការណ៍ណែនាំអនុវត្តឱ្យកាន់តែល្អប្រសើរ ។

អស់លោកអ្នកអាចផ្តល់នូវការរិះគន់ទាំងនោះតាមរយៈទូរស័ព្ទ អ៊ីមែល ឬសរសេរមកកាន់នាយកទំនាក់ទំនង ដែលប្រចាំការនៅតាមការិយាល័យ STREAM ប្រចាំការតាមប្រទេសរបស់អស់លោកអ្នក ។

**ការិយាល័យ STREAM ប្រចាំប្រទេសកម្ពុជាមានអាស័យដ្ឋានដូចខាងក្រោម :**

ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ ( នាយកដ្ឋានជលផល)
អាគារលេខ ១៨៦ វិថី ព្រះនរោត្តម ខ័ណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទលេខ : (៨៥៥ ២៣) ២១០ ១៥៤
ទូរសារលេខ : (៨៥៥ ២៣) ២១០ ១៥៤
អ៊ីមែល : **cfdo@online>com>kh**

**ការិយាល័យ STREAM ប្រចាំតំបន់ :**

អាគារ ណាកា (NACA) នាយកដ្ឋានជលផល
បរិវេណ សាកលវិទ្យាល័យកាសេតសាទ
ផ្លូវ ផាហ្វុលយ៉ូស៊ីន សង្កាត់ បែងឃេន
ទីក្រុងបាងកក ១០៩០៣ ប្រទេសថៃឡង់
ទូរសព្ទលេខ : ៦៦២ ៥៦១ ១៧២៨/២៩
ទូរសារលេខ : ៦៦២ ៥៦១ ១៧២៧
អ៊ីមែល : **stream@enaca.org**
**STREAM** គេហទំព័រ : www.streaminitiative.org